**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល**

លេខ......៣៥៥......ស.ភ.រ

# សេចក្តីជូនដំណឹង

អនុលោមតាមសេចក្តីសម្រេចលេខ៣៩៥១ មស.សសរ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការជំនាន់ទី៨ សាលាភូមិន្ទរដ្ឋបាល សូមជូនដំណឹងដល់ និស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងឡើងទៅ និងនិស្សិតដែលទើបបញ្ចប់ការសិក្សាឆ្នាំទី២ដោយជោគជ័យក្នុងឆ្នាំ២០១៨នេះ និងមន្ត្រីរាជការទាំងអស់ ឱ្យបានជ្រាបថា សាលា នឹងរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការ ជំនាន់ទី៨ ចំនួន១២០នាក់ បេក្ខជនត្រូវជ្រើសរើសភាសាជាមុនក្នុងការដាក់ពាក្យ សម្រាប់ការបណ្តុះបណ្តាលឆ្នាំ២០១៩។

- លក្ខខណ្ឌនៃការជ្រើសរើស សូមមើលក្នុងសេចក្តីសម្រេចលេខ៣៩៥១ មស.សសរ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ
- កាលបរិច្ឆេទបំពេញពាក្យតាម Online ចាប់ផ្តើមពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ តទៅ តាមគេហទំព័រ sms.era.gov.kh ឬអាចមកបំពេញពាក្យសុំប្រឡងតាម Online នៅសាលាភូមិន្ទរដ្ឋបាល
- កាលបរិច្ឆេទ នៃការទទួលពាក្យ នឹងចាប់ផ្តើមពីថ្ងៃ២៦ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង ១៧ម៉៣០នាទី ជាពេលផុតកំណត់
- សូមភ្ជាប់មកជាមួយនូវរូបថតថ្មី ៤x៦ ចំនួន៤សន្លឹក (ផ្ទៃខាងក្រោយពណ៌ស) និងឯកសារច្បាប់ដើម រួមមាន សំបុត្រកំណើត សញ្ញាបត្រ(ចាប់ពីបរិញ្ញាបត្ររងឡើងទៅ),ប្រកាសតាំងស៊ប់ និងលិខិតបញ្ជាក់បច្ចុប្បន្នភាព(សម្រាប់មន្ត្រីរាជការ) រួមទាំងច្បាប់ថតចម្លងដោយបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
- ការប្រឡងប្រជែងនឹងប្រព្រឹត្តនៅក្នុងសប្តាហ៍ទី៤ ខែវិច្ឆិកា ឆ្នាំ២០១៨ រីឯកាលបរិច្ឆេទជាក់ស្តែង នឹងត្រូវប្រកាសបិទផ្សាយជូននៅពេលក្រោយ និងនៅលើគេហទំព័ររបស់សាលាភូមិន្ទរដ្ឋបាល។

<u>បញ្ជាក់៖</u>

- ការដាក់ពាក្យសុំសិទ្ធិប្រឡងតម្លៃ ៤៥.០០០៛(សែសិបប្រាំពាន់រៀលគត់)។

ចំពោះព័ត៌មានលម្អិតផ្សេងៗទៀត មាននៅលើគេហទំព័រសាលា www.era.gov.kh ឬសូមទំនាក់ទំនងជាមួយការិយាល័យរដ្ឋបាល ឬតាមលេខទូរស័ព្ទរៀងរាល់ម៉ោងធ្វើការដូចខាងក្រោម៖

០១១ ៩៩ ៥៨ ៥៤ ០១៥ ៩៦ ៩៧ ២១ ០៩៧ ៩៧ ៥១ ៥៧២

អាស្រ័យហេតុនេះ សូមបេក្ខជន ជានិស្សិត និងមន្ត្រីរាជការទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១ រោច ខែភទ្របទ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៨

**សាលាភូមិន្ទរដ្ឋបាល**

**ចម្លងជូន៖**
- សមាជិកក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៣៩៤១ មស.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការលើកទី៨

### រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ-បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩៣ អនក្របក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- យោងសំណើរបស់នាយកសាលាភូមិន្ទរដ្ឋបាល ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨



ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# សម្រេច

**ប្រការ ១**._ ត្រូវបានអនុញ្ញាតឱ្យបើកការបណ្តុះបណ្តាលមន្ត្រីក្រមការ លើកទី៨ ចំនួន ១២០នាក់ នៅសាលាភូមិន្ទរដ្ឋបាល ដោយត្រូវធ្វើការជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការតាមក្រសួងស្ថាប័ន និងនិស្សិត។ បេក្ខជនដែលប្រឡងជាប់នឹងត្រូវរៀនរយៈពេល ១ឆ្នាំ។ កាលបរិច្ឆេទប្រឡងប្រជែងនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា ឆ្នាំ២០១៨។

**ប្រការ ២**._ លក្ខខណ្ឌជ្រើសរើស ៖

- បេក្ខជនទាំងពីរភេទជានិស្សិតត្រូវមានអាយុយ៉ាងច្រើនបំផុត២៨ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយត្រូវមានសញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សាទាបបំផុតកម្រិតទុតិយភូមិ បូក២ឆ្នាំ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- បេក្ខជនទាំងពីរភេទជាមន្ត្រីរាជការត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- ត្រូវមានលិខិតថ្កោលទោស ចេញដោយក្រសួងយុត្តិធម៌ នៅពេលប្រឡងជាប់ជាស្ថាពរ
- ត្រូវមានលិខិតពិនិត្យសុខភាពចេញដោយនាយកដ្ឋានពេទ្យការងារ នៅក្រោយពេលប្រឡងជាប់ជាស្ថាពរ។
- បញ្ជីបេក្ខជនដែលអនុញ្ញាតឱ្យចូលធ្វើវិញ្ញាសាប្រឡងប្រជែង ត្រូវកំណត់ដោយសេចក្តីសម្រេច របស់ក្រសួងមុខងារសាធារណៈ។

**ប្រការ ៣**._ វិញ្ញាសាប្រឡងប្រជែងរួមមាន ៖ វិញ្ញាសាសរសេរលើកទី១ និងវិញ្ញាសាសរសេរលើកទី២

**ក- វិញ្ញាសាសរសេរលើកទី១ ៖**

សំណួរពហុចម្លើយ និងអធិប្បាយខ្លី "រយៈពេល ២ម៉ោង៣០នាទី"

**មានតែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើកទី១តែប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឱ្យចូលរួមប្រឡងវិញ្ញាសាសរសេរលើកទី២។**

**ខ- វិញ្ញាសាសរសេរលើកទី២ ៖**

១- អធិប្បាយ ជ្រើសរើស ពាក់ព័ន្ធនឹងចំណេះដឹងទូទៅ ( ច្បាប់ រដ្ឋបាល, សេដ្ឋកិច្ច, វប្បធម៌ទូទៅ) និងសំណួរខ្លី ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ, អក្សរសាស្ត្រ, ភូមិសាស្ត្រ, សីលធម៌ ពលរដ្ឋវិទ្យា, អរិយធម៌វប្បធម៌ "រយៈពេល ៣ម៉ោង" មេគុណ ១

២- ភាសាអង់គ្លេស ឬភាសាបារាំង "រយៈពេល ១ម៉ោង ៣០នាទី" មេគុណ ១

**ប្រការ ៤**._ វិញ្ញាសាសរសេរត្រូវរក្សាអនាមិកភាព។ វិញ្ញាសានីមួយៗត្រូវកែជាពីរលើក និងត្រូវផ្តល់ពិន្ទុលើ ១០០។

**ប្រការ ៥**._ ក្រោយការប្រឡងប្រជែង ប្រធានគណៈមេប្រយោគត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាសាលា។ របាយការណ៍នេះ នឹងត្រូវបញ្ជូនទៅក្រសួងមុខងារសាធារណៈ។

**ប្រការ ៦** ._ ការទទួលស្គាល់ជាសិស្សមន្ត្រីក្រមការសាលាភូមិន្ទរដ្ឋបាល ត្រូវធ្វើដោយសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។ សិស្សត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ តាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**ប្រការ ៧** ._ ក្រុមប្រឹក្សាសាលា នាយកសាលាភូមិន្ទរដ្ឋបាល ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល:**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ